THE SCHOOL DISTRICT OF PHILADELPHIA

**OFFICE OF THE SUPERINTENDENT**
440 North Broad Street
Philadelphia, PA 19130

**Dr. Tony B. Watlington Sr., Ed.D.**
អគ្គនាយកក្រសួងអប់រំ

ថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០២៤

ជូនចំពោះ ក្រុមគ្រួសាររបស់ ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា៖

វិធីជ្រើសរើសសាលា *Find Your Fit* របស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា អនុញ្ញាតឱ្យសិស្សដែលរៀនថ្នាក់មុនមត្តេយ្យ ដល់ថ្នាក់ទី ១១ ដាក់ពាក្យសុំចូលរៀននៅសាលាណាមួយរបស់ក្រសួងអប់រំដែលមានកន្លែងទំនេរ ទាំងនៅក្រៅតំបន់ជិតខាង ឬក្រៅតំបន់សាលារបស់ពួកគេ សម្រាប់ឆ្នាំសិក្សាខាងមុខ។ **វិធីជ្រើសរើសសាលា *Find Your Fit* សម្រាប់ឆ្នាំសិក្សា ២០២៥-២០២៦ បើកនៅថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០២៤ វេលាម៉ោង ៤ រសៀល ហើយបិទនៅថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០២៤ វេលាម៉ោង ១១:៥៩ យប់។**

ក្នុងអំឡុងឆ្នាំសិក្សា ២០២៣-២០២៤ ក្រសួងអប់រំបានទទួលមតិយោបល់ពីសិស្ស និងក្រុមគ្រួសារជាបន្ត ទាក់ទងនឹងការកែលម្អវិធីជ្រើសរើសសាលារៀន។ ដោយមូលហេតុនេះ ការិយាល័យចុះឈ្មោះ និងចាត់តាំងសិស្ស (OSEP) និង ការិយាល័យបច្ចេកវិទ្យាព័ត៌មាន (IT) បានសហការជាមួយក្រុមផ្តល់បច្ចេកវិទ្យាថ្មី Avela ដើម្បីធ្វើការផ្លាស់ប្តូរជាច្រើនផ្អែកលើមតិយោបល់របស់អ្នក។ ប្រព័ន្ធជ្រើសរើសសាលាដែលបានកែសម្រួលថ្មីរបស់យើងនឹងផ្តល់នូវវិធីដាក់ពាក្យដែលកាន់តែងាយស្រួល។ **នៅថ្ងៃទី ៥ ខែ សីហា យើងបានចាប់ផ្តើមក្បួនស្វែងរកសាលាតាមកុំព្យូទ័រដែលងាយស្រួលប្រើជាងមុន ហៅថា Explore (រុករក) ដែលផ្តល់ព័ត៌មានដ៏ទូលំទូលាយអំពីសាលារៀននីមួយៗ។** នេះគឺជាអ្វីៗដែលសិស្សានុសិស្ស និងក្រុមគ្រួសារដែលមានបំណងចូលរួមក្នុងវិធីជ្រើសរើសសាលា សម្រាប់ឆ្នាំសិក្សា ២០២៥-២០២៦ អាចរំពឹងទុក នៅពេលចាប់ផ្តើមលិខិតដាក់ពាក្យក្នុងរដូវស្លឹកឈើជ្រុះនេះ។

- **នៅក្នុងប្រព័ន្ធជ្រើសរើសសាលាថ្មីរបស់យើង បេក្ខជនម្នាក់ៗនឹងអាចដាក់ជម្រើស សាលា/កម្មវិធី ល្អៗលើសគេទាំងប្រាំរបស់ពួកគេតាមលំដាប់ – ដែលជាការកែសម្រួលដ៏សំខាន់បំផុត។** កាលពីឆ្នាំមុនមានការពិចារណាស្ទើរតែទាំងស្រុងតែលើ សិទ្ធិទទួល និងកៅអីដែលមាន។ ប្រព័ន្ធថ្មីនេះប្រើក្បួនដោះស្រាយដែលឈ្មោះរង្វាន់ណូបែល ដែលត្រូវបានរចនាឡើងដើម្បីបង្កើតការផ្តល់ជូនដ៏ល្អបំផុត ដោយផ្អែកលើសិទ្ធិទទួលរបស់បេក្ខជន និងចំណូលចិត្តរបស់ពួកគេ យោងទៅលើរបៀបដែលពួកគេដាក់ជម្រើសសាលារបស់ពួកគេទៅតាមលំដាប់។ ជារឿងសំខាន់ដែលត្រូវចាំថា ត្រូវជ្រើសរើសសាលា ៥ ។ ជម្រើសមិនគ្រប់ចំនួននឹងមិនបង្កើនឱកាសក្នុងការទទួលការផ្តល់ជូននោះទេ – តាមពិត ឱកាសនឹងថយចុះ។
- **បេក្ខជនអាចទទួលបានការផ្តល់ជូនមួយ ឬការផ្តល់ជូនសូន្យ ក្នុងអំឡុងពេលនៃដំណាក់កាលឆ្លើយតបដំបូង។** ការផ្តល់ជូននឹងត្រូវបានធ្វើឡើងដោយផ្អែកលើលំដាប់ដែលបេក្ខជនដាក់ជម្រើសសាលាទាំងប្រាំរបស់

ពួកគេ សិទ្ធិទទួលរបស់បេក្ខជន និងកៅអីដែលមាននៅ សាលា/កម្មវិធី។

- **បេក្ខជននឹងនៅតែមានឈ្មោះនៅក្នុងបញ្ជីរង់ចាំ*សម្រាប់តែ* សាលាដែលមានលំដាប់ខ្ពស់ជាង ដែលពួកគេមិនទទួលបានការផ្តល់ជូន។** ឧទាហរណ៍ ប្រសិនបើសិស្សដាក់សាលា ៥ តាមលំដាប់ដែលចង់បាន ហើយបានទទួលការផ្តល់ជូនសាលាលំដាប់ទី ៣ របស់ពួកគេ ពួកគេនឹងនៅតែមានឈ្មោះនៅក្នុងបញ្ជីរង់ចាំសម្រាប់សាលាលំដាប់ទី ១ និងទី ២ របស់ពួកគេ ប៉ុន្តែនឹងត្រូវបានបដិសេធដោយស្វ័យប្រវត្តិសម្រាប់កៅអីនៅសាលាលំដាប់ទី ៤ និងទី ៥ របស់ពួកគេ។ ប្រសិនបើពួកគេទទួលការផ្តល់ជូនបញ្ជីរង់ចាំបន្ទាប់ទៀតសម្រាប់ជម្រើសទី ២ របស់ពួកគេ ពួកគេអាចទទួលយកការផ្តល់ជូននោះ ហើយនឹងបដិសេធដោយស្វ័យប្រវត្តិនូវការផ្តល់ជូនជម្រើសទីបីរបស់ពួកគេកាលពីដើមដំបូង ប៉ុន្តែអនុញ្ញាតឱ្យពួកគេបន្តនៅក្នុងបញ្ជីរង់ចាំសម្រាប់ជម្រើសទី ១ របស់ពួកគេ។ ក្រោយមកពួកគេអាចទទួលយកកៅអីនៅជម្រើសទីមួយរបស់ពួកគេប្រសិនបើផ្តល់ជូន។
- នៅតែមានការពិចារណាតាមលេខស៊ីពកូដ ប៉ុន្តែលេខស៊ីពកូដបានផ្លាស់ប្តូរបន្តិច។ លេខស៊ីពកូដទាំងប្រាំមួយគឺ 19140, 19133, 19132, 19136, 19124, និង 19134 ។
- ខណៈពេលដែលព័ត៌មាននៃការវាយតម្លៃ រួមទាំង PSSA នៅតែជាតម្រូវការក្នុងការទទួលកៅអីនៅសាលាដែលផ្អែកលើលក្ខណៈវិនិច្ឆ័យ **ប្រព័ន្ធនៃការដាក់ពាក្យនឹងលែងទទួលយក ប្រព័ន្ធនៃការវាយតម្លៃតាមវិធីផ្សេងទៀតរបស់រដ្ឋផិនស៊ីលវេនញ៉ា (PASA) ជាការវាយតម្លៃតាមស្តង់ដារដែលបានអនុម័តទៀតហើយ។**

ក្នុងនាមជាក្រសួងអប់រំ យើងមានការរំភើបចិត្តអំពីការកែសម្រួលទាំងនេះ ចំពោះវិធីជ្រើសរើសសាលា *Find Your Fit* ។ យើងជឿជាក់ថា ប្រព័ន្ធថ្មីនេះនឹងធ្វើឱ្យមានភាពប្រសើរឡើងសម្រាប់ចំណូលចិត្តរបស់សិស្ស ផ្តល់នូវការផ្តល់ជូនដល់សិស្សកាន់តែច្រើនពីដំបូង សម្រួលដល់ការទទួលយកកាន់តែច្រើនក្នុងរយៈពេលដ៏ខ្លី ហើយនាំឱ្យមានការកាត់បន្ថយពេលវេលាដើម្បីបំពេញកៅអីដែលនៅទំនេរទូទាំងសាលារបស់យើង។ យើងនឹងផ្តល់ព័ត៌មានលម្អិតបន្ថែមអំពីវិធីជ្រើសរើសសាលា *Find Your Fit* រួមទាំង ពេលវេលា លក្ខណៈវិនិច្ឆ័យ និងធនធានដែលមានប្រយោជន៍នៅរដូវស្លឹកឈើជ្រុះនេះ។ នៅពេលនេះ យើងសូមអញ្ជើញលោកអ្នកឱ្យស្វែងរកចម្លើយចំពោះសំណួរបន្ថែមរបស់លោកអ្នក និងស្វែងយល់បន្ថែមអំពីការជ្រើសរើសសាលាដោយចូលទៅកាន់គេហទំព័រ schoolselect.philasd.org ។

សូមរីករាយនឹងរដូវក្តៅរបស់លោកអ្នក!

ក្នុងភាពជាដៃគូ

Tony

Tony B. Watlington Sr., Ed.D.
អគ្គនាយកក្រសួងអប់រំ
ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា